ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២១ លេខ៨៥ ត្រីមាសទី០៤ ឆ្នាំ២០២១

# រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


៩-១១-២០២១ -ព្រះរាជក្រម នស/រកម/១១២១/០១៧ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ស្តីពីការរៀបចំក្នុងពេលអន្តរកាលនិងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ១០៤៩១


### ២~ព្រះរាជក្រឹត្យ


២៨-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៧៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ អស់លោក ចំនួន ២ រូប ១០៥០៤


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


១៥-១២-២០២១ -អនុក្រឹត្យលេខ ២៤៤ អនក្រ.បក ស្តីពី ការកាត់ឆ្វៀលដីទំហំ ៤៨ ហិកតា ៥៩ អា ៦៣ សង់ទីអា ស្ថិតក្នុងភូមិអូរស្គាន សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ចេញពីផលប៉ះពាល់ជាមួយសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហួរ លីង (ខេមបូឌា) អ៊ីនធើណេសិនណល អ៊ិនសឺរេន ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងប្រទានកម្មជាកម្មសិទ្ធជូនឈ្មោះ **ម៉ី កែវមរកត** ១០៥០៥

២៨-១២-២០២១ -អនុក្រឹត្យលេខ ២៦៣ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ១០៥០៨

២៨-១២-២០២១ -អនុក្រឹត្យលេខ ២៦៤ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ១០៥១០

៣០-១២-២០២១ -អនុក្រឹត្យលេខ ៦០១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១០៥១២


## III~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


១២-៨-២០២១ -ប្រកាសអន្តរក្រសួងលេខ ៤៩៨ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យចំណូលសម្រាប់ឆ្នាំ ២០២១ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១០៥១៤

១១-១០-២០២១ -ប្រកាសអន្តរក្រសួងលេខ ៦១០ សហវ.ប្រក ស្តីពី ការតែងតាំងភ្នាក់ងារបើកផ្តល់ នៅបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ១០៥១៧

១១-១០-២០២១ -ប្រកាសអន្តរក្រសួងលេខ ៦១១ សហវ.ប្រក ស្តីពី ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន នៅបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ១០៥២១

**២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

៥-១១-២០២១ -ប្រកាសលេខ ៣៩៨ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អូសិន អឹកែវឹល មេនូហ្វេកឆឺរីង ឯ.ក បង្កើតសាខារោងចក្រ កាត់ដេរសម្លៀកបំពាក់ ១០៥២៤

៥-១១-២០២១ -ប្រកាសលេខ ៣៩៩ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សូឡា ឡុង ភីវី-ថេក (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិត និងផ្គុំដំឡើងបន្ទះសូឡា និងគ្រឿងបង្គុំ ១០៥២៧

៨-១១-២០២១ -ប្រកាសលេខ ៤០០ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ដាគ្វាន ថេកស្តាយ (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ១០៥៣០

៨-១១-២០២១ -ប្រកាសលេខ ៤០១ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេ.វ៉ាយ អជីសស៊ីហ្គាម៉ិន ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ១០៥៣៣

៨-១១-២០២១ -ប្រកាសលេខ ៤០៣ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វ៊ូវឈូន ប្រត ហ្វ៊ូតវែរ ឯ.ក បង្កើតរោងចក្រ ផលិតស្បែកជើង និងគ្រឿងបន្សំស្បែកជើង ១០៥៣៦

**៣~ទីស្តីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល**

២-២-២០២១ -ប្រកាសលេខ ០១៥១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ទនៈលេខ ០១៥១ រថ.អប្រក.លអ ចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៥៣៩

២-២-២០២១ -ប្រកាសលេខ ០១៥៣ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ទនៈលេខ ០១៥៣ រថ.អប្រក.លអ ចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៥៤៣

២-២-២០២១ -ប្រកាសលេខ ០១៥៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ទនៈលេខ ០១៥៤ រថ.អប្រក.លអ ចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៥៤៧

២-២-២០២១ -ប្រកាសលេខ ០១៥៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ទនៈលេខ ០១៥៦ រថ.អប្រក.លអ ចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៥៥១

២-២-២០២១ -ប្រកាសលេខ ០១៥៩ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ទនៈលេខ ០១៥៩ រថ.អប្រក.លអ ចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៥៥៥

២-២-២០២១ -ប្រកាសលេខ ០១៦០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ទនៈលេខ ០១៦០ រថ.អប្រក.លអ ចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៥៥៩

៣-២-២០២១ -ប្រកាសលេខ ០១៦១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ទនៈលេខ ០១៦១ រថ.អប្រក.លអ ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៥៦៣

៣-២-២០២១ -ប្រកាសលេខ ០១៦២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០១៦២ រថ.អប្រក.លអ ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៥៦៧

៣-២-២០២១ -ប្រកាសលេខ ០១៦៣ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០១៦៣ រថ.អប្រក.លអ ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៥៧១

៣-២-២០២១ -ប្រកាសលេខ ០១៦៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
រួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០១៦៤ រថ.អប្រក.លអ ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៥៧៥

៣-២-២០២១ -ប្រកាសលេខ ០១៦៥ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០១៦៥ រថ.អប្រក.លអ ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៥៧៩

៣-២-២០២១ -ប្រកាសលេខ ០១៦៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០១៦៦ រថ.អប្រក.លអ ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៥៨៣

៣-២-២០២១ -ប្រកាសលេខ ០១៦៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០១៦៧ រថ.អប្រក.លអ ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៥៨៧

៣-២-២០២១ -ប្រកាសលេខ ០១៦៨ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០១៦៨ រថ.អប្រក.លអ ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៥៩១

៣-២-២០២១ -ប្រកាសលេខ ០១៦៩ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០១៦៩ រថ.អប្រក.លអ ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៥៩៥

៣-២-២០២១ -ប្រកាសលេខ ០១៧០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០១៧០ រថ.អប្រក.លអ ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៥៩៩

៣-២-២០២១ -ប្រកាសលេខ ០១៧១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០១៧១ រថ.អប្រក.លអ ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៦០៣

៣-២-២០២១ -ប្រកាសលេខ ០១៧២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០១៧២ រថ.អប្រក.លអ ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០២១ ១០៦០៧

១-៣-២០២១ -ប្រកាសលេខ ០២៥២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០២៥២ រថ.អប្រក.លអ ចុះថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០២១ ១០៦១១

# ព្រះរាជក្រម

នស/រកម/១១២១/០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០០៤/០០៤ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ស្តីពីការរៀបចំក្នុងពេលអន្តរកាលនិងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ស្តីពីការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ

**មាត្រា១ .-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ស្តីពីការរៀបចំក្នុងពេលអន្តរកាលនិងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខានៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ និងអង្គការសហប្រជាជាតិបានចុះហត្ថលេខានៅទីក្រុងញូវយ៉កនៃសហរដ្ឋអាមេរិកនាថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២ .-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងបន្ថែមនេះ។

**មាត្រា៣ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ អង្គារ ៥កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ២០២១

នស.រកម.១១២១.០០៨

ន សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦២៤ សរ.ប្រក

## សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
- បានឃើញកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាពជូនឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខាក្នុងនាមរាជរដ្ឋាភិបាលកម្ពុជាលើកិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យស្តីពីការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ។

ដើម្បីជាសក្ខីភាព **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដោយមានសិទ្ធិពេញលេញតាមអំណាចច្បាប់ បានចុះហត្ថលេខាខាងក្រោមលើសិទ្ធិប្រទាននេះ។

ថ្ងៃ ចន្ទ ៩កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ សីហា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

*Kingdom of Cambodia*

រាជរដ្ឋាភិបាល

*Royal Government*

ជាតិ សាសនា ព្រះមហាក្សត្រ

*Nation Religion King*

N°: 24 DFP

Phnom Penh, 16 August 2021

**DELEGATION OF FULL POWERS**

- Having seen the Constitution of the Kingdom of Cambodia;
- Having seen the Royal Decree NS/RKT/0918/925 dated 6 September 2018 on the Nomination of the Government of the Kingdom of Cambodia;
- Having seen the Royal Decree NS/RKT/0320/421 dated 30 March 2020 on the Nomination and Modification of the composition of the Government of the Kingdom of Cambodia;
- Having seen the Royal Kram NS/RKM/0618/012 dated 28 June 2018 promulgating the Law on the Organization and Functioning of the Council of Ministers;
- Having seen the Royal Kram No. NS/RKM/0801/12 dated 10 August 2001 promulgating the Law on the Establishment of the Extraordinary Chambers in the Courts of Cambodia;
- Having Seen the Agreement between the United Nations and the Royal Government of Cambodia concerning the prosecution under Cambodian law of crimes committed during the period of Democratic Kampuchea; and
- Referring to the request of the Standing Deputy Prime Minister, Minister in charge of the Office of the Council of Ministers.

**THE ROYAL GOVERNMENT**

Delegates herewith Full Powers to His Excellency **Bin Chhin**, Standing Deputy Prime Minister, Minister in charge of the Office of the Council of Ministers, to sign, on behalf of the Government of the Kingdom of Cambodia, the Addendum to the Agreement between the United Nations and the Royal Government of Cambodia concerning the prosecution under Cambodian law of crimes committed during the period of Democratic Kampuchea on the Transitional Arrangements and the Completion of Work of the Extraordinary Chambers.

In witness whereof, the undersigned, the Prime Minister of the Kingdom of Cambodia, with Full Powers duly entrusted to him, has signed this Delegation of Full Powers.

**Prime Minister**

**Samdech Akka Moha Sena Padei Techo HUN SEN**

# កិច្ចព្រមព្រៀងបន្ថែម
# នៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ
# ទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម
# ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
# ស្តីពី
# ការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ

ដោយរម្លឹកអំពីកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ នៅរាជធានីភ្នំពេញ (តទៅនេះហៅថា "កិច្ចព្រមព្រៀង")

ដោយហេតុថា ភាគីនៃ"កិច្ចព្រមព្រៀង"យល់ព្រមគ្នាថា ក្រោយពីការបញ្ចប់រាល់កិច្ចដំណើរការនីតិវិធីតុលាការអនុលោមតាមមាត្រា១នៃ"កិច្ចព្រមព្រៀង" អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តការងារសេសសល់សំខាន់ៗមួយចំនួនដូចមានកំណត់នៅក្នុងកិច្ចព្រមព្រៀងបន្ថែមនេះ

ដោយហេតុថា ភាគីនៃ"កិច្ចព្រមព្រៀង"ជឿជាក់ថា ដោយយោងទៅដល់លក្ខណៈកាត់បន្ថយយ៉ាងធំធេងនៃមុខងារសេសសល់ អង្គជំនុំជម្រះវិសាមញ្ញគួរមានចំនួនបុគ្គលិកដែលសមាមាត្រជាមួយនឹងមុខងាររបស់ខ្លួនដែលត្រូវបានកាត់បន្ថយនោះ

ដោយហេតុថា ភាគីនៃ"កិច្ចព្រមព្រៀង"បានធ្វើការពិភាក្សាគ្នាស្តីពីការរៀបចំក្នុងពេលអន្តរកាលសម្រាប់ការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញនិងការបំពេញមុខងារសេសសល់

អាស្រ័យហេតុនេះ ក្នុងពេលនេះ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងគ្នាដូចខាងក្រោម៖

## មាត្រា ១

## ការរៀបចំក្នុងពេលអន្តរកាល

ក្រោយពេលបញ្ចប់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះនេះត្រូវលែងមានការិយាល័យនៅអង្គជំនុំជម្រះវិសាមញ្ញទៀតហើយ។ បន្ទាប់ពីលែងមានការិយាល័យនៅអង្គជំនុំជម្រះវិសាមញ្ញ ចៅក្រមទាំងអស់ត្រូវទទួលបានបៀវត្សរ៍ដោយសមាមាត្រទៅនឹងការងារ ហើយត្រូវបំពេញការងារពីចម្ងាយលើកលែងតែនៅពេលដែលតម្រូវឱ្យមានវត្តមាននៅអង្គជំនុំជម្រះវិសាមញ្ញទៅតាមសំណើរបស់ប្រធានអង្គជំនុំជម្រះប៉ុណ្ណោះ។

## មាត្រា ២

## មុខងារសេសសល់

១. ក្រោយពេលបញ្ចប់កិច្ចដំណើរការនីតិវិធីដោយអនុលោមតាមមាត្រា១នៃ"កិច្ចព្រមព្រៀង" រួមទាំងបណ្ដឹងសាទុក្ខណាមួយនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះវិសាមញ្ញត្រូវបន្តបំពេញមុខងារនានាសម្រាប់រយៈពេលបីឆ្នាំដំបូង ដូចតទៅៈ ពិនិត្យមើលទៅលើពាក្យសុំនានានិងដំណើរការនីតិវិធីសើរើទៅលើសាលដីកាស្ថាពរ ផ្ដល់ការការពារដល់ជនរងគ្រោះនិងសាក្សី ដាក់ទណ្ឌកម្មឬបញ្ជូនទៅអាជ្ញាធរពាក់ព័ន្ធនូវការជ្រៀតជ្រែកនានាដោយចេតនាក្នុងកិច្ចការរដ្ឋបាលតុលាការឬការផ្ដល់សក្ខីកម្មក្លែងក្លាយ គ្រប់គ្រងការអនុវត្តទោសព្រមទាំងការតាមដានការប្រព្រឹត្តចំពោះទណ្ឌិត ថែទាំ រក្សាទុកនិងគ្រប់គ្រងបណ្ណសាររបស់ខ្លួនរួមទាំងការធ្វើចំណាត់ថ្នាក់ឡើងវិញនៃឯកសារសំណុំរឿងទាំងអស់ ឆ្លើយតបទៅនឹងសំណើសុំចូលពិនិត្យមើលឯកសារ ផ្សព្វផ្សាយព័ត៌មានដល់សាធារណជនពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញ និងត្រួតពិនិត្យមើលការអនុវត្តការផ្ដល់សំណងដែលបានផ្ដល់ឱ្យភាគីដើមបណ្ដឹងរដ្ឋប្បវេណីទៅតាមករណីចាំបាច់។

២. អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាត្រូវពិនិត្យមើលវឌ្ឍនភាពនៃមុខងារទាំងនេះក្រោយពេលបីឆ្នាំដំបូង បន្ទាប់មកអង្គជំនុំជម្រះវិសាមញ្ញត្រូវបន្តបំពេញមុខងារទាំងនេះឬមុខងារមួយផ្នែកក្នុងបិរវេលាដែលត្រូវកំណត់ដោយភាគីទាំងពីរ។

៣. ការស្នើសុំឱ្យសើរើនូវសាលដីកាស្ថាពរ អាចធ្វើបានតែក្នុងអំឡុងពេលដែលទណ្ឌិតនៅមានជីវិតនិងត្រូវធ្វើឡើងដោយទណ្ឌិតឬសហព្រះរាជអាជ្ញាតែប៉ុណ្ណោះ។

៤. ប្រសិនបើទណ្ឌិតមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានការបន្ធូរបន្ថយទោស ការដោះលែងមុនពេលកំណត់ឬការដោះលែងដោយមានលក្ខខណ្ឌ រាជរដ្ឋាភិបាលកម្ពុជាត្រូវជូនដំណឹងដល់អង្គជំនុំជម្រះវិសាមញ្ញអំពីស្ថានភាពនេះ។ ការបន្ធូរបន្ថយទោស ការដោះលែងមុនពេលកំណត់ឬការដោះលែងដោយមានលក្ខខណ្ឌអាចធ្វើទៅបានលុះត្រាតែអង្គជំនុំជម្រះតុលាការកំពូលជាអ្នកសម្រេចដោយផ្អែកលើផលប្រយោជន៍យុត្តិធម៌និងគោលការណ៍ទូទៅនៃច្បាប់។

៥. ចៅក្រម សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីត្រូវទទួលបានបៀវត្សរ៍សមាមាត្រទៅនឹងការងារដែលបានបំពេញដូចបានកំណត់ក្នុងកថាខណ្ឌទី១ខាងលើ ហើយពួកគេត្រូវបំពេញការងារពីចម្ងាយ លើកលែងតែមុខងាររបស់ខ្លួនតម្រូវឱ្យមកបង្ហាញខ្លួននៅអង្គជំនុំជម្រះវិសាមញ្ញ។ ចំពោះករណីរបស់ចៅក្រម ការមកបង្ហាញខ្លួនលុះត្រាតែមានសំណើពីប្រធានអង្គជំនុំជម្រះរបស់ខ្លួន។ កិច្ចប្រជុំពេញអង្គរបស់តុលាការត្រូវធ្វើពីចម្ងាយ ហើយការធ្វើវិសោធនកម្មវិធាននផ្ទៃក្នុងត្រូវសម្រេចពីចម្ងាយដោយនីតិវិធីជាលាយលក្ខណ៍អក្សរ។

៦. នៅពេលចាប់ផ្ដើមមុខងារដូចមានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំផ្ដល់បញ្ជីឈ្មោះបេក្ខជនចៅក្រមអន្តរជាតិបន្ថែម អនុលោមតាមកថាខណ្ឌទី៥ នៃមាត្រា៣នៃ"កិច្ចព្រមព្រៀង" ដើម្បីធានាថាមានចំនួនចៅក្រមអន្តរជាតិគ្រប់គ្រាន់ដើម្បីបំពេញមុខងារទៅតាមកថាខណ្ឌទី១នៃមាត្រានេះ ក្នុងករណីដែលចៅក្រមអន្តរជាតិដែលបានតែងតាំងរួចហើយ មិនអាចបំពេញមុខងាររបស់ខ្លួនបានក្នុងករណីចាំបាច់។ រាជរដ្ឋាភិបាលកម្ពុជាក៏ត្រូវរៀបចំបញ្ជីឈ្មោះបេក្ខជនចៅក្រមជាតិស្រដៀងគ្នាដែរ ដើម្បីធានាថាមានចៅក្រមជាតិមកបំពេញការងារក្នុងករណីដែលចៅក្រមជាតិដែលបានតែងតាំងរួចហើយមិនអាចបំពេញមុខងាររបស់ខ្លួនបានក្នុងករណីចាំបាច់។

## មាត្រា ៣

## បណ្ណសារ

១. អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាយល់ព្រមគ្នាថា ជាការសំខាន់ដែលធានាថាបណ្ណសាររបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវបានរក្សាទុកដោយអនុលោមតាមបទដ្ឋានអន្តរជាតិហើយសាធារណជនអាចចូលមើលបានយ៉ាងទូលំទូលាយ។

២. ក្នុងគោលបំណងដើម្បីថែរក្សានិងលើកកម្ពស់កេរដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញដែលជាផ្នែកនៃមុខងារសេសសល់របស់ខ្លួន អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុញ្ញាតឱ្យសាធារណជនមានសិទ្ធិចូលមើលបាននូវសំណៅអេឡិចត្រូនិក និងសំណៅជាក្រដាសនៃបណ្ណសារសាធារណៈ។

៣. អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាត្រូវមានដូចគ្នានូវសំណុំបណ្ណសារពេញលេញរបស់អង្គជំនុំជម្រះវិសាមញ្ញ ដែលរួមបញ្ចូលនូវសំណុំឯកសារនិងសម្ភារៈទាំងអស់។ ក្រោយពេលបញ្ចប់កិច្ចដំណើរការនីតិវិធីដោយអនុលោមតាមមាត្រា១នៃ"កិច្ចព្រមព្រៀង" អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបាននូវសំណុំបណ្ណសារសាធារណៈពេញលេញ។ ក្រោយពេលបញ្ចប់មុខងារសេសសល់ដោយអនុលោមតាមមាត្រា២នៃកិច្ចព្រមព្រៀងបន្ថែមនេះ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបានឯកសារនិងសម្ភារៈសាធារណៈបន្ថែមដែលមាន ព្រមទាំងឯកសារនិងសម្ភារៈសម្ងាត់ពេញលេញ។

## មាត្រា ៤

## ការអនុម័តយល់ព្រម

ដើម្បីចងភាតព្វកិច្ចដល់ភាគី កិច្ចព្រមព្រៀងបន្ថែមនេះត្រូវទទួលការអនុម័តយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ និងត្រូវផ្ដល់សច្ចាប័នដោយព្រះរាជាណាចក្រកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ក្នុងការទទួលបានការផ្ដល់សច្ចាប័ននេះឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

## មាត្រា ៥

## ការអនុវត្តនៅកម្ពុជា

កិច្ចព្រមព្រៀងបន្ថែមនេះត្រូវអនុវត្តជាច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ក្រោយពេលផ្តល់សច្ចាប័នទៅតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃច្បាប់ផ្ទៃក្នុងរបស់ព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងសមត្ថកិច្ចក្នុងការចុះសន្ធិសញ្ញា។

## មាត្រា ៦

## ការចូលជាធរមាន

កិច្ចព្រមព្រៀងបន្ថែមនេះ ត្រូវចូលជាធរមាននៅថ្ងៃដែលភាគីទាំងពីរបានជូនដំណឹងគ្នាទៅវិញទៅមកជាលាយលក្ខណ៍អក្សរថា លក្ខខណ្ឌតម្រូវតាមផ្លូវច្បាប់សម្រាប់ការចូលជាធរមាន ត្រូវបានបំពេញរួចរាល់។

ធ្វើនៅទីក្រុងញូវយ៉ក និងរាជធានីភ្នំពេញ នាថ្ងៃទី២១ខែសីហាឆ្នាំ២០២១ និងថ្ងៃទី២៦ ខែសីហាឆ្នាំ២០២១ជាបន្តបន្ទាប់ ជាពីរច្បាប់ដើមជាភាសាអង់គ្លេសនិងភាសាខ្មែរ។ ក្នុងករណីមានភាពខុសគ្នាភាសាអង់គ្លេសត្រូវយកជាភាសាគោល។

**តំណាងរាជរដ្ឋាភិបាលកម្ពុជា**

**ប៊ិន ឈិន**
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**តំណាងអង្គការសហប្រជាជាតិ**

**មីហ្គែល ដឺសែរប៉ា សូអារ៉េស**
អគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់
និងជាអ្នកច្បាប់របស់ អ.ស.ប.

# Addendum to the Agreement between the Royal Government of Cambodia and the United Nations concerning the prosecution under Cambodian law of crimes committed during the period of Democratic Kampuchea on the Transitional Arrangements and the Completion of Work of the Extraordinary Chambers

**RECALLING** the Agreement between the United Nations and the Royal Government of Cambodia concerning the prosecution under Cambodian law of crimes committed during the period of Democratic Kampuchea, done on 6 June 2003 at Phnom Penh (hereinafter the "Agreement");

**WHEREAS** the parties to the Agreement agree that upon the completion of all judicial proceedings under Article 1 of the Agreement, the Extraordinary Chambers will need to carry out a number of essential residual functions identified in this Addendum;

**WHEREAS** the parties to the Agreement are convinced that in view of the substantially reduced nature of the residual functions, the Extraordinary Chambers should be comprised of such number of staff that is commensurate with its reduced functions;

**WHEREAS** the parties to the Agreement have engaged in consultations on transitional arrangements for the completion of the work of the Extraordinary Chambers and on the performance of residual functions:

**NOW THEREFORE** the United Nations and the Royal Government of Cambodia have agreed as follows:

**Article 1**

**Transitional Arrangements**

Upon the completion of proceedings before any chamber of the Extraordinary Chambers, all judges of that Chamber shall be de-installed from the Extraordinary Chambers. Following their de-installation, the judges shall be remunerated on a pro-rata basis for any work performed, and they shall work remotely except when required to be present at the Extraordinary Chambers at the request of the President of the Chamber.

**Article 2**

**Residual Functions**

1. Upon the completion of the proceedings under Article 1 of the Agreement, including any appeals related thereto before the Supreme Court Chamber, the Extraordinary Chambers shall continue to carry out the following functions for an initial period of three years: review applications and conduct proceedings for revision of final judgments; provide for the protection of victims and witnesses; sanction or refer to the appropriate authorities any wilful interference with the administration of justice or provision of false testimony; supervise the enforcement of sentences as well as monitor the treatment of convicted prisoners; maintain, preserve and manage its archives, including the declassification of documents and materials; respond to requests for access to documents; disseminate information to the public regarding the Extraordinary Chambers; and monitor the enforcement of reparations awarded to Civil Parties, as required.

2. The United Nations and the Royal Government of Cambodia shall review the progress of these functions after the initial three-year period, following which the Extraordinary Chambers will continue to perform these functions, or some part thereof, for a further period to be determined between the parties.

3. An application for revision of final judgment may only be filed during the lifetime of the convicted person by the convicted person or the co-prosecutors.

4. If a convicted person is eligible for commutation of sentence, early release, or parole, the Royal Government of Cambodia shall notify the Extraordinary Chambers accordingly. There shall only be a commutation of sentence, early release, or parole if the Supreme Court Chamber so decides on the basis of the interests of justice and general principles of law.

5. Judges, co-prosecutors, defence counsels and Civil Party Lead Co-Lawyers shall be remunerated on a pro-rata basis when required to perform the functions identified in paragraph 1 of this article, and they shall work remotely except when their functions require their attendance in person at the Extraordinary Chambers. In the case of the judges, this would be at the request of the President of their respective chambers. Any judicial plenary sessions shall be conducted remotely and amendments of the Internal Rules shall be decided remotely by written procedure.

6. Upon the commencement of the functions identified in paragraph 1 of this article, the Secretary-General shall undertake to provide a list of nominees for international judges further to paragraph 5 of Article 3 of the Agreement to ensure that there are a sufficient number of international judges available to carry out the functions under paragraph 1 of this article should any appointed international judge be unavailable to serve when required. The Royal Government of Cambodia shall similarly ensure the availability of Cambodian judges should any appointed Cambodian judge be unavailable to serve when required.

## Article 3
## Archives

1. The United Nations and the Royal Government of Cambodia agree that it is vital to ensure that the archives of the Extraordinary Chambers are preserved in accordance with international standards and that they are as broadly accessible as possible.

2. For the purpose of preserving and promoting the legacy of the Extraordinary Chambers, as part of its residual functions, the Extraordinary Chambers shall provide electronic access to, and printed copies of, the public archives to the public.

3. The United Nations and the Royal Government of Cambodia shall each have a complete set of the archives of the Extraordinary Chambers, including all documents and materials. Upon the completion of the proceedings under Article 1 of the Agreement, the United Nations and the Royal Government of Cambodia shall each receive a complete set of the public archives. Upon the completion of the residual functions under Article 2 of this Addendum, the United Nations and the Royal Government of Cambodia shall each receive any additional public documents and materials, as well as a complete set of classified documents and materials.

**Article 4**
**Approval**

To be binding on the parties, the present Addendum must be approved by the General Assembly of the United Nations and ratified by the Kingdom of Cambodia. The Royal Government of Cambodia will make its best endeavors to obtain this ratification by the earliest possible date.

**Article 5**
**Application within Cambodia**

The present Addendum shall apply as law within the Kingdom of Cambodia following its ratification in accordance with the relevant provisions of the internal law of the Kingdom of Cambodia regarding competence to conclude treaties.

**Article 6**

**Entry into force**

The present Addendum shall enter into force on the day after both parties have notified each other in writing that the legal requirements for the entry into force have been complied with.

Done at New York and Phnom Penh on 11 August 2021 and 26 August 2021, respectively, in two originals in both the Khmer and English languages. In a case of divergence, the English text shall prevail.

| For the Royal Government of Cambodia | For the United Nations |
|---|---|
| **Bin Chhin** | **Miguel de Serpa Soares** |
| Standing Deputy Prime Minister | Under-Secretary-General for Legal Affairs |
| Minister in charge of the Office of the Council of Ministers | and United Nations Legal Counsel |

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៥៧៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**ឱ្យ**

គ្រឿងឥស្សរិយយស**មុនីសារាភ័ណ្ឌ** ថ្នាក់**មហាសេនា**

១- Mr. LE DANG DZUNG

២- Mr. TAO DUC THANG

ការល. ២១១២.៥៩៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២១

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...២៤៤.....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ឆ្វៀលដីទំហំ៤៨ហិកតា៥៩អា៦៣សង់ទីអា ស្ថិតក្នុងភូមិអូរស្ពាន សង្កាត់ ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ចេញពីផលប៉ះពាល់ជាមួយសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហួរ លីង (ខេមបូឌា) អ៊ីនធើណេសិនណាល អ៊ិនសីរេន ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងប្រទានកម្មជាកម្មសិទ្ធិជូនឈ្មោះ ម៉ី កែវមរកត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបទបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ឆ្វៀលដីទំហំ៤៨ហិកតា៥៩អា៦៣សង់ទីអា ស្ថិតក្នុងភូមិអូរស្ពាន សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ដូចមានផែនទីបង្ហាញទីតាំង និងចំណុចនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យ ចេញពីផលប៉ះពាល់ជាមួយសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហួរ លីង (ខេមបូឌា) អ៊ីនធើណេសិនណល អ៊ិនសីវេន ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ។

**មាត្រា ២.-**

ផ្តល់សិទ្ធិជាកម្មសិទ្ធិលើផ្ទៃដីទំហំ៤៨ហិកតា៥៩អា៦៣សង់ទីអា ស្ថិតក្នុងភូមិអូរស្ពាន សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ជូនឈ្មោះ ម៉ី កែវមរកត។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃពុធ ១១កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**អន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ២៤៨ អនក្រ.បក ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០២១

ផែនទីបង្ហាញទីតាំងដីស្នើសុំកាត់ឆ្វៀលចេញពីគម្របព្រៃឈើឆ្នាំ២០០២ និងផលប៉ះពាល់ជាមួយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ហួរ លីង (ខេមបូឌា) អ៊ិនធើណេសិនណល អ៊ិនស៊ីអេន ស្ថិតក្នុងភូមិអូរស្គាន សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋឈ្មោះ ម៉ី កែវមរកត




| No | X | Y | No | X | Y |
|---|---|---|---|---|---|
| 1 | 741568 | 1374171 | 28 | 741958 | 1374901 |
| 2 | 741415 | 1374577 | 29 | 742022 | 1374931 |
| 3 | 741468 | 1374595 | 30 | 742058 | 1374947 |
| 4 | 741495 | 1374612 | 31 | 742095 | 1374956 |
| 5 | 741504 | 1374644 | 32 | 742166 | 1374978 |
| 6 | 741489 | 1374679 | 33 | 742226 | 1374998 |
| 7 | 741450 | 1374705 | 34 | 742344 | 1375026 |
| 8 | 741405 | 1374690 | 35 | 742404 | 1375044 |
| 9 | 741383 | 1374684 | 36 | 742525 | 1375109 |
| 10 | 741366 | 1374730 | 37 | 742589 | 1375088 |
| 11 | 741367 | 1374744 | 38 | 742692 | 1375257 |
| 12 | 741374 | 1374754 | 39 | 742769 | 1375238 |
| 13 | 741464 | 1374823 | 40 | 742860 | 1375238 |
| 14 | 741530 | 1374843 | 41 | 742842 | 1375121 |
| 15 | 741566 | 1374857 | 42 | 742794 | 1375087 |
| 16 | 741610 | 1374871 | 43 | 742744 | 1375062 |
| 17 | 741650 | 1374886 | 44 | 742625 | 1375003 |
| 18 | 741674 | 1374894 | 45 | 742459 | 1374907 |
| 19 | 741693 | 1374895 | 46 | 742444 | 1374833 |
| 20 | 741711 | 1374894 | 47 | 742286 | 1374769 |
| 21 | 741736 | 1374886 | 48 | 742145 | 1374710 |
| 22 | 741758 | 1374875 | 49 | 742025 | 1374659 |
| 23 | 741779 | 1374867 | 50 | 741960 | 1374633 |
| 24 | 741803 | 1374860 | 51 | 741916 | 1374619 |
| 25 | 741837 | 1374857 | 52 | 741845 | 1374211 |
| 26 | 741870 | 1374860 | 53 | 741663 | 1374183 |
| 27 | 741909 | 1374873 | | | |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ** : ២៦៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការផ្ទេរឥណទានថវិកា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃ សុក្រ ១១កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃ អង្គារ ១៥កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ១ ៤៨៥ ៤០០ ០០០ រៀល (មួយប៊ីលានបួនរយប៉ែតសិបប្រាំលានបួនរយពាន់រៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦២ (អត្ថប្រយោជន៍សង្គម) ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១។

**មាត្រា២ .-**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ប្រព័ន្ធសៀ្វងបម្រុងកម្ពុជា ដោយបង្វែរចូលគណនីតម្កល់មូលនិធិប្រាក់បម្រុងសម្រាប់គាំទ្រប្រព័ន្ធសៀ្វងបម្រុងកម្ពុជា។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៩ រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៦៤ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃ សុក្រ ១១កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃ អង្គារ ១៥កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

✗

**<u>សម្រេច</u>**

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៣៨៣ ៧០០ ០០០ រៀល (បីរយប៉ែតសិបបីលានប្រាំពីររយពាន់រៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមក ជំពូក ៦២ (អត្ថប្រយោជន៍សង្គម) ជូនក្រសួងពាណិជ្ជកម្ម សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១។

**មាត្រា២ .-**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីទូទាត់ថវិកាជូនក្រុមហ៊ុន NVC Corporation Co., Ltd. សម្រាប់ការបំពេញស្តុកទឹកសុទ្ធរាជរដ្ឋាភិបាលចំនួន ២១ ០០០ កេស។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៩ រោច ខែ មិគសិរ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦០១ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា១.**- បំពាក់មេដាយ**មុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនចំនួន ១២រូប ដែលបានចូលរួមជួយកសាងសមិទ្ធផលនានា នៅវត្តរតនវនារាមបន្ទាយឆ្មារ និងវត្តច័ន្ទស៊ីសាមគ្គីរតនារាម ឃុំគូប ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ចំណាយអស់ថវិកាសរុបចំនួន ១ ០៨៦ ៩៥៨ ដុល្លារអាមេរិក កន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ**មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា**

១- ព្រះខេមញាណ រ៉េន ស៊ីណាត

២- ព្រះសរណញាណ ថា ប៊ុនឡាត់

៣- លោក បៀវ ថាន

៤- លោក ធឿន ប៊ុនថន

៥- អ្នកស្រី យ៉ាំង អ៊ួយលីន

ខ-មេដាយ**មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ**

១- លោក ចិក ម៉ៅ
២- លោក តេង គីមសេង
៣- លោក លន់ សុវណ្ណារ៉ា
៤- អ្នកស្រី ស៊ិន ម៉ូឡាឌី
៥- អ្នកស្រី តិច សុភ័ក្រ
៦- លោក ហេង មករា
៧- លោក សែម រចនា

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៤៥៨ សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតរង្វង់ថវិកាចំណូលសម្រាប់ឆ្នាំ២០២១ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី**
**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២០៣ សហវ.ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**ប្រការ១.-**

បង្កើតរជ្ជទេយ្យចំណូលនៅក្រសួងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីប្រមូលចំណូលឆ្នាំ២០២១ មានដូចខាងក្រោម÷

- អនុគណនី ៧៣០២៣ (ផលពីការបង្កើតសហគ្រាស) ចំនួនទឹកប្រាក់ ១ ៥០០ ០០០ ០០០៖០០
- អនុគណនី ៧៣០៤៤ (សេវាសំណង់) ចំនួនទឹកប្រាក់ ១២ ០០០ ០០០ ០០០៖០០

**ប្រការ២.-**

ចំនួនទឹកប្រាក់អតិបរមាដែលអនុញ្ញាតទុកនៅក្នុងបេឡាមានកំណត់ត្រឹមចំនួន ២ ០០០ ០០០៖០០(ពីរលានរៀលគត់)។

**ប្រការ៣.-**

សេចក្តីសម្រេចទាំងឡាយណា ដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយដ្ឋានរតនាគារជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋាន

សម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

